**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន

## ទិវាពិភពលោក ដើម្បីសុខភាព និងសុវត្ថិភាពការងារ ២៨ មេសា ក្រោមប្រធានបទ "ភាពងាយរងគ្រោះផ្នែកសុខភាព និងសុវត្ថិភាពការងាររបស់កម្មករវ័យក្មេង" ខេត្តកណ្តាល ថ្ងៃច័ន្ទ ៨រោច ខែពិសាខ ឆ្នាំច សំរិទ្ធស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៨

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយសហការជាមួយអង្គការអន្តរជាតិខាងការងារ-ជប៉ុន និងគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (ILO-BFC) នឹងរៀបចំទិវាពិភពលោកដើម្បីសុខភាព និងសុវត្ថិភាពការងារ ២៨ មេសា ក្រោមប្រធានបទ "**ភាពងាយរងគ្រោះផ្នែកសុខភាព និងសុវត្ថិភាពការងាររបស់កម្មករវ័យក្មេង**" ដែលនឹងប្រព្រឹត្តទៅនាថ្ងៃច័ន្ទ ៨រោច ខែពិសាខ ឆ្នាំច សំរិទ្ធស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៨ នៅតំបន់អភិវឌ្ឍន៍វិហារសួគ៌ (7NG) ខេត្តកណ្តាល។

នេះជាឆ្នាំទី១៣ហើយ ដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រារព្ធទិវាពិភពលោកដើម្បីសុខភាព និងសុវត្ថិភាពការងារ ក្នុងគោលបំណងផ្សព្វផ្សាយអំពីទំហំនៃគ្រោះថ្នាក់ការងារនិងជំងឺវិជ្ជាជីវៈ និងបំផុសការយល់ដឹងជាសាធារណៈ ស្តីពីសុខភាព និងសុវត្ថិភាពការងារ ដើម្បីកាត់បន្ថយគ្រោះថ្នាក់នៅកន្លែងធ្វើការ ព្រមទាំងទាញការគាំទ្រពីស្ថាប័នពាក់ព័ន្ធ អង្គការនិយោជក និងអង្គការកម្មករនិយោជិត។

ទិវានេះ នឹងមានការចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ថ្នាក់ដឹកនាំក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកណ្តាល តំណាងអង្គការអន្តរជាតិខាងការងារ តំណាងគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា នាយកតំបន់អភិវឌ្ឍន៍វិហារសួគ៌ តំណាងនិយោជក និងសហជីព ព្រមទាំងតំណាងស្ថាប័នពាក់ព័ន្ធ ម្ចាស់សហគ្រាស គ្រឹះស្ថាននានា និងកម្មករនិយោជិតនៅតំបន់អភិវឌ្ឍន៍វិហារសួគ៌ (7NG) ខេត្តកណ្តាល សរុបចំនួនជាង ១៣០០នាក់។

ថ្ងៃ អង្គារ ១០ កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០១៨

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩